មេតង្គ ឯកអគ្គរាជទូតកម្ពុជាប្រចាំរាជាណាចក្រថៃឡង់ដ៍ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ៨ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ២៥ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការ**

**សំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ទេសាភិបាលនៃ ធនាគារជាតិនៃកម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងារ

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់រៀបចំ និងតាមដានការអនុវត្តន៍អនុស្សារណៈ ស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និង សំរាប់ជាដៃគូក្នុងកិច្ចប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ពិសេសជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ នៅក្នុងក្របខ័ណ្ឌ «កម្មវិធី ផ្តត់ផ្គង់កំណែតម្រូវរចនាសម្ព័ន្ធ »។

**មាត្រា២ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១–ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២–ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤–តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| ៥–តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦–តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | សមាជិក |
| ៧–តំណាងក្រសួងផែនការ | សមាជិក |
| ៨–តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៩–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

ក្នុងករណីអវត្តមានរបស់ប្រធាននិងអនុប្រធាន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកជាប្រធាន និងអនុប្រធានជាស្វ័យប្រវត្តិ ។

**មាត្រា ៣ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់អង្គភាពសេដ្ឋកិច្ចនៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ។

**មាត្រា ៤ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង និងស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំ ដើម្បីដោះស្រាយការងារនៃការរៀបចំ និងការតាមដានការអនុវត្តន៍អនុស្សារណៈស្តីពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៥ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើការតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៦ :** គណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ប្រចាំនៅប្រទេសកម្ពុជា អោយចូលរួមប្រជុំក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

**មាត្រា ៧ :** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលនៃធនាគារជាតិកម្ពុជា សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ ២៦ អនក្រ.បក

## ស្តីពីការកំណត់ឡើងវិញនូវព្រំប្រទល់រដ្ឋបាលក្រុងកែបបន្ថែម ជាមួយខេត្តកំពត ត្រង់ចំណុចចំការបី